# កម្រិតប្រកាសអាសន្ន និងសកម្មភាពជម្លៀសខ្លួន
## [ការពារជីវិតរបស់អ្នកដោយខ្លួនឯង]

### កម្រិតប្រកាសអាសន្ន

នៅពេលដែលក្រុងចេញបញ្ជាអំពីព័ត៌មានជម្លៀសខ្លួន ដូចជាការជម្លៀសមនុស្សចាស់។ល។ (កម្រិតប្រកាសអាសន្នទី 3) ឬការបង្គាប់ឱ្យជម្លៀសខ្លួន (កម្រិតប្រកាសអាសន្នទី 4) សូមជម្លៀសខ្លួនចេញពីកន្លែងគ្រោះថ្នាក់ជាបន្ទាន់។ ម្យ៉ាងវិញទៀត នៅពេលដែលទីភ្នាក់ងារឧតុនិយមចេញផ្សាយព័ត៌មានអាកាសធាតុ ដែលស្មើនឹងកម្រិតប្រកាសអាសន្នទី 3 កម្រិតទី 4 សូមធ្វើការសម្រេចចិត្តជម្លៀសដោយខ្លួនឯង ទោះបីជាមិនមានការចេញបញ្ជាដូចជាការបង្គាប់ឱ្យជម្លៀសខ្លួនក៏ ដោយ។

| កម្រិតប្រកាសអាសន្ន | ព័ត៌មានពីទីភ្នាក់ងារឧតុនិយម។ល។ | | | ព័ត៌មានជម្លៀសខ្លួន | សកម្មភាពដែលប្រជាពលរដ្ឋត្រូវធ្វើ |
|---|---|---|---|---|---|
| | គ្រោះមហន្តរាយភ្លៀងធ្លាក់ខ្លាំង/បាក់ដី | ទឹកឡើងខ្ពស់ | ទឹកជន់លិចទន្លេ | | |
| 5 | ការប្រកាសអាសន្នពិសេសអំពីករណីភ្លៀងធ្លាក់ខ្លាំង | | ព័ត៌មានអំពីការកើតមានទឹកជន់លិច | ការធានាសុវត្ថិភាពពេលអាសន្ន<br>*នេះមិនចាំបាច់ជាព័ត៌មានដែលនឹងត្រូវបញ្ចេញនោះទេ | គ្រោះថ្នាក់ដល់អាយុជីវិត ធានាសុវត្ថិភាពជាបន្ទាន់!<br>ស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិត ដែលមិនអាចធ្វើការជម្លៀសដោយសុវត្ថិភាពនោះទេ ។ ផ្លាស់ទីជាបន្ទាន់ទៅកន្លែងដែលមានសុវត្ថិភាពជាងកន្លែងដែលអ្នកនៅបច្ចុប្បន្ន។ |
| ត្រូវប្រាកដថាបានជម្លៀសខ្លួនមុនពេលកម្រិតប្រកាសអាសន្នទី 4! | | | | | |
| 4 | ព័ត៌មានអំពីការប្រកាសអាសន្នគ្រោះមហន្តរាយបាក់ដី | ការប្រកាសអាសន្នពិសេសអំពីករណីទឹកឡើងខ្ពស់<br>ការប្រកាសអាសន្នអំពីករណីទឹកឡើងខ្ពស់ | ព័ត៌មានអំពីគ្រោះថ្នាក់នៃករណីទឹកជន់លិច | ការបង្គាប់ឱ្យជម្លៀសខ្លួន | ការជម្លៀសមនុស្សទាំងអស់ចេញពីកន្លែងគ្រោះថ្នាក់ |
| 3 | ការប្រកាសអាសន្នអំពីករណីភ្លៀងធ្លាក់ខ្លាំង<br>ការប្រកាសអាសន្នអំពីករណីទឹកជំនន់ | ការប្រកាសព្រមានដែលមានលទ្ធភាពខ្ពស់ក្នុងការប្តូរជាការប្រកាសអាសន្នអំពីករណីទឹកឡើងខ្ពស់ | ព័ត៌មានប្រកាសអាសន្នអំពីករណីទឹកជន់លិច | ការជម្លៀសមនុស្សចាស់ | ជម្លៀសមនុស្សចាស់ជាដើម ចេញពីកន្លែងគ្រោះថ្នាក់<br>អ្នកដែលត្រូវការពេលយូរដើម្បីជម្លៀស ចូរចាប់ផ្តើមជម្លៀសចេញ។ |
| 2 | ការប្រកាសព្រមានដែលមានលទ្ធភាពខ្ពស់ក្នុងការប្តូរជាការប្រកាសអាសន្នអំពីករណីភ្លៀងធ្លាក់ខ្លាំង<br>ការប្រកាសព្រមានអំពីករណីភ្លៀងធ្លាក់ខ្លាំង<br>ការប្រកាសព្រមានអំពីករណីទឹកជំនន់ | ការប្រកាសព្រមានអំពីករណីទឹកឡើងខ្ពស់ | ព័ត៌មានព្រមានអំពីករណីទឹកជន់លិច | | បញ្ជាក់អំពីសកម្មភាពជម្លៀសដោយខ្លួនឯង<br>ប្រើផែនទីបង្ហាញគ្រោះមហន្តរាយ។ល។ ដើម្បីបញ្ជាក់ឡើងវិញនូវហានិភ័យគ្រោះមហន្តរាយនៃផ្ទះរបស់អ្នក និងបញ្ជាក់ឡើងវិញអំពីមធ្យោបាយដែលអ្នកអាចទទួលបានព័ត៌មានជម្លៀសខ្លួន។ |
| 1 | ព័ត៌មានព្រមានជាមុន<br>(លទ្ធភាពនៃកម្រិតប្រុងប្រយ័ត្ន) | | | | បង្កើនការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ |

### អំពីសកម្មភាពជម្លៀស

#### ● ចំណុចដែលត្រូវចងចាំនៅពេលជម្លៀស

ការជម្លៀសខ្លួន គឺមិនមែនគ្រាន់តែជាការទៅកន្លែងជម្លៀសខ្លួនទេ ។ «ការជម្លៀស»មានន័យថា«ជៀសវាង»«គ្រោះមហន្តរាយ»។ វិធីសាស្ត្រនៃការជម្លៀសមានភាពខុសគ្នាអាស្រ័យលើស្ថានភាពនៅពេលនោះ និងពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ ត្រូវដឹងថា «ជីវិតរបស់ខ្លួនឯងត្រូវការពារដោយខ្លួនឯង» ហើយសម្រេចចិត្តថាអ្នកគួរធ្វើយ៉ាងណាជាប្រចាំថ្ងៃ។

**ការជម្លៀស** … ជម្លៀសទៅកាន់កន្លែងជម្លៀសដែលបានកំណត់ សាច់ញាតិ ផ្ទះអ្នកស្គាល់គ្នា សណ្ឋាគារ ផ្ទះសំណាក់។ល។

**ធានាសុវត្ថិភាពក្នុងផ្ទះ** … ប្រសិនបើអគារមានសុវត្ថិភាព ហើយវាមានគ្រោះថ្នាក់ក្នុងការចេញទៅខាងក្រៅ សូមស្នាក់នៅក្នុងផ្ទះដើម្បីធានាសុវត្ថិភាពរបស់អ្នក។



#### ● ភាពខុសគ្នារវាងកន្លែងជម្លៀសខ្លួន និងជម្រកជម្លៀស

**កន្លែងជម្លៀស** … គឺជាកន្លែងគេចផុតពីគ្រោះថ្នាក់នៃគ្រោះមហន្តរាយ និងការពារខ្លួនអ្នកជាបណ្តោះអាសន្ន។ (ឧទាហរណ៍៖ កន្លែងដែលមិនត្រូវបានជន់លិចដោយទឹកជន់លិចទន្លេ ទឹកឡើងខ្ពស់ ឬរលកស៊ូណាមិ និងកន្លែងដែលមិនត្រូវបានខូចខាតដោយការរញ្ជួយដី)

**ជម្រកជម្លៀស** … គឺជាកន្លែងសម្រាប់អ្នកដែលមិនអាចរស់នៅក្នុងផ្ទះ ឬអ្នកដែលមិនអាចត្រឡប់ទៅផ្ទះរបស់ពួកគេវិញ ដោយសារគ្រោះមហន្តរាយ អាចរស់នៅបានក្នុងរយៈពេលជាក់លាក់ណាមួយ។





# ស្វែងយល់អំពីករណីទឹកជន់លិចទន្លេ

### ទឹកជន់លិចខាងក្រៅ និងទឹកជន់លិចខាងក្នុង

នៅពេលដែលទឹកហូរហៀរពីច្រាំងទន្លេ ឬបំផ្លាញច្រាំង អគារ និងវាលស្រែត្រូវបានជន់លិច នោះគេហៅថាទឹកជន់លិចខាងក្រៅ។ ប្រសិនបើទឹកជន់លិចខាងក្រៅកើតឡើង តំបន់ធំទូលាយអាចនឹងជន់លិច ហើយគ្រោះមហន្តរាយធំអាចនឹងកើតឡើង។
ម្យ៉ាងវិញទៀត ទោះបីទឹកមិនហៀរពីច្រាំងក៏ដោយ ក៏ទឹកភ្លៀងដែលធ្លាក់មកមិនអាចហូរចូលទន្លេបានឡើយ ហើយអគារ ដី និងផ្លូវថ្នល់ត្រូវលិចក្នុងទឹក ដែលហៅថាទឹកជន់លិចខាងក្នុង។ ទោះបីការជន់លិចទឹកមានទំហំតូចជាងការលិចទឹកខាងក្រៅក៏ដោយ តែងាយស្រួលក្នុងការកើតឡើងនៅគ្រប់ទីកន្លែង។




តំបន់បាក់ស្រុតរាលដាលយ៉ាងឆាប់រហ័សហើយទឹកដែលហូរចេញដោយកម្លាំងខ្លាំងវាយលុកផ្ទះជាដើម។




ភ្លៀងធ្លាក់ខ្លាំងធ្វើឱ្យកម្ពស់ទឹកទន្លេឡើងខ្ពស់ បង្កការលំបាកដល់ការបង្ហូរទឹក បណ្តាលឱ្យលូទឹកស្ទះ និងប្រព័ន្ធលូហូរហៀរ។

### អំពីការប៉ាន់ស្មានទឹកជន់លិចទន្លេនៅក្នុងផែនទីតំបន់គ្រោះថ្នាក់

**នេះគឺជាការនិម្មិតដោយខេត្តអៃឈិ នៃស្ថានភាពទឹកជន់លិចដែលនឹងកើតឡើងប្រសិនបើទន្លេបានលិចលង់ដោយសារតែភ្លៀងធ្លាក់ខ្លាំងដ៏ធំបំផុតដែលអាចកើតមាន។ ប្រូបាប៊ីលីតេនៃភ្លៀងធ្លាក់ខ្លាំងដ៏ធំបំផុតដែលរំពឹងទុក គឺប្រហែលម្តងរៀងរាល់ 1.000 ឆ្នាំម្តង។**

*ទឹកលិចដោយសារទឹកឡើងខ្ពស់ និងទឹកខាងក្នុងមិនត្រូវបានគេគិតគូរទេដូច្នេះទឹកលិចអាចកើតមានឡើងសូម្បីតែនៅតំបន់ផ្សេងក្រៅពីតំបន់ដែលទឹកលិចត្រូវបានរំពឹងទុក (តំបន់ដែលមានផាត់ពណ៌)។




### ប្រការគួរប្រយ័ត្នក្នុងករណីទឹកជន់លិច



ចូរប្រមូលព័ត៌មានត្រឹមត្រូវតាមទូរទស្សន៍ វិទ្យុ និងអ៊ីនធឺណិត។ល។
ប្រសិនបើអ្នកមានអារម្មណ៍ថាមានគ្រោះថ្នាក់ ចូរជម្លៀសខ្លួន ឱ្យបានឆាប់រហ័ស។



ប្រសិនបើទឹកជ្រៅដល់ត្រឹមជង្គង់ សូម្បីតែមនុស្សពេញវ័យ ក៏ពិបាកដើរដែរ។
ការជម្លៀសទៅកន្លែងខ្ពស់ក្នុងអគារក៏ជាជម្រើសមួយដែរ។



មានគ្រោះថ្នាក់ជាច្រើនដែលមើលមិនឃើញនៅក្រោមទឹក ដូចជាគម្របលូចំហ លូទឹក ដីមិនរាបស្មើជាដើម ដូច្នេះសូមប្រើឈើវែងៗ ធ្វើជាឈើច្រត់សម្រាប់ដើរ ដើម្បីការពារសុវត្ថិភាពពេលដើរ។



ចូរស្ពាយកាបូបសង្គ្រោះបឋមនៅលើខ្នង ដើម្បីទុកឱ្យដៃទាំងពីរ ប្រើការផ្សេងៗតាមដែលអាចធ្វើទៅបាន។

# ស្វែងយល់អំពីករណីទឹកឡើងខ្ពស់

## យន្តការនៃការកើតទឹកឡើងខ្ពស់

នៅពេលដែលព្យុះទីហ្វុងខិតមកជិត ឬបោកបក់មកលើឆ្នេរសមុទ្រ សម្ពាធបរិយាកាសទាប ធ្វើឱ្យផ្ទៃទឹកសមុទ្រត្រូវបានបឺតឡើង បណ្ដាលឱ្យកម្រិតទឹកកើនឡើងខុសពីធម្មតា ហើយនៅពេលជាមួយគ្នានោះ ព្យុះដែលបក់ពីមាត់ច្រាំងមកកាន់ឆ្នេរក៏រុញទឹកសមុទ្រមកលើដីគោក។ បាតុភូតនេះត្រូវបានគេហៅថាទឹកឡើងខ្ពស់។ ប្រសិនបើទឹកឡើងខ្ពស់ស្របពេលជាមួយនឹងខ្យល់ខ្លាំង ការខូចខាតមកលើដីគោកនឹងកាន់តែធំ។




### ការបឺតឡើងដោយសម្ពាធទាប

ដោយសារតែសម្ពាធបរិយាកាសទាបនៅជិតចំណុចកណ្ដាលនៃ
ព្យុះទីហ្វុងឬតំបន់សម្ពាធទាបដូច្នេះខ្យល់នៅក្នុងតំបន់នោះធ្វើសកម្មភាពបឺតផ្ទៃទឹកសមុទ្រឡើងដែលបណ្ដាលឱ្យកម្រិតទឹកសមុទ្រកើនឡើង។ នៅពេលដែលសម្ពាធបរិយាកាសធ្លាក់ចុះ 1 hPa កម្រិតទឹកសមុទ្រកើនឡើងប្រហែល 1 cm។

### ការបឺតឡើងដោយខ្យល់

នៅពេលដែលមានខ្យល់ខ្លាំងដែលបណ្ដាលមកពីព្យុះទីហ្វុង បក់ពីសមុទ្រទៅកាន់ឆ្នេរ នោះទឹកសមុទ្រត្រូវបានបក់បោកឆ្ពោះទៅឆ្នេរសមុទ្រ បណ្ដាលឱ្យកម្ពស់ទឹកសមុទ្រកើនឡើង។ ការកើនឡើងនៃនីវ៉ូទឹកសមុទ្រ គឺសមាមាត្រទៅនឹងការ៉េនៃល្បឿនខ្យល់។ ប្រសិនបើល្បឿនខ្យល់កើនឡើង 2 ដង នីវ៉ូទឹកសមុទ្រនឹងកើនឡើង 4 ដង។

## គ្រោះមហន្តរាយទឹកឡើងខ្ពស់ធំៗនាពេលកន្លងមក

នៅក្នុងព្យុះទីហ្វុងឈូងសមុទ្រអ៊ីសេឆ្នាំ1959 គ្រោះមហន្តរាយដែលបង្កឡើងដោយព្យុះភ្លៀង និងទឹកឡើងខ្ពស់បានកើតឡើងនៅទូទាំងខេត្ត ជាពិសេសនៅឈូងសមុទ្រអ៊ីសេ។ នៅក្នុងទីក្រុងនេះ ផ្ទះប្រជាពលរដ្ឋចំនួន 2.317 ខ្នងត្រូវបានបំផ្លាញទាំងស្រុង ផ្ទះចំនួន 581 ខ្នងត្រូវបានបំផ្លាញដោយផ្នែក ឬជន់លិច ហើយអគារមិនមែនលំនៅដ្ឋានចំនួន 1.979 អគារ។ល។ ក៏ត្រូវបានបំផ្លាញដោយផ្នែក ឬទាំងស្រុងផងដែរ។
ព្យុះទីហ្វុងលេខ 18 ក្នុងឆ្នាំ2009 បានបង្កការខូចខាតដោយគ្រោះមហន្តរាយបាក់ដី និងទឹកជន់លិចនៅតំបន់ជាច្រើន ដោយសារភ្លៀងធ្លាក់ខ្លាំង ខ្យល់ខ្លាំង រលកខ្ពស់ និងទឹកឡើងខ្ពស់ ហើយនៅក្នុងទីក្រុងនេះ បានរងការខូចខាតធ្ងន់ធ្ងរ ក្នុងនោះផ្ទះចំនួន 1 ខ្នងត្រូវបានបំផ្លាញទាំងស្រុង ផ្ទះចំនួន 186 ខ្នងរងការខូចខាតដោយផ្នែក ផ្ទះចំនួន 46 ខ្នងផ្សេងទៀតត្រូវបានជន់លិច។

## អំពីការប៉ាន់ស្មានទឹកឡើងខ្ពស់នៅក្នុងផែនទីតំបន់គ្រោះថ្នាក់

នេះគឺជាការនិម្មិតឡើងដោយខេត្តអៃឈិអំពីស្ថានភាពទឹកជន់លិចដែលបង្កឡើងដោយទឹកឡើងខ្ពស់ដ៏ធំបំផុតដែលអាចកើតមាន។ ទឹកឡើងខ្ពស់ដ៏ធំបំផុតត្រូវបានសន្មត់ថា នៅពេលដែលព្យុះទីហ្វុងដ៏ធំបំផុតដែលចូលមកជិតប្រទេសជប៉ុនឆ្លងកាត់ផ្លូវនៃជំនោរខ្ពស់បំផុតដោយសារឥទ្ធិពលរបស់ព្យុះទីហ្វុងនៅពេលកម្រិតជំនោរឡើងខ្ពស់បំផុត។
ព្យុះទីហ្វុងដ៏ធំបំផុតត្រូវបានគេប៉ាន់ស្មានថាជាកម្រិតព្យុះទីហ្វុងមីរ៉ុតុនៅឆ្នាំ1934 (911,6hPaនៅពេលមកដល់ជ្រោយមីរ៉ុតុ)ដែលរក្សាសម្ពាធបរិយាកាស (910 hPa) នៅពេលមកដល់ច្រាំង ហើយឆ្លងកាត់ក្នុងល្បឿននៃថ្នាក់ខ្យល់ព្យុះទីហ្វុង ឈូងសមុទ្រអ៊ីសេ (73 km/h)។ ប្រូបាប៊ីលីតេនៃព្យុះទីហ្វុងដ៏ធំបំផុតដែលរំពឹងទុកគឺប្រហែលម្ដងរៀងរាល់ 500 ឆ្នាំម្ដង។
លើសពីនេះ យើងសន្មតថាជាសេណារីយ៉ូដ៏អាក្រក់បំផុត ដូចជាការគិតគូរពីការកើនឡើងនៃកម្ពស់ទឹក / ការជន់លិចទន្លេ និងការបាក់ច្រាំង ដោយសារឥទ្ធិពលទឹកឡើងខ្ពស់។
*សូមប្រុងប្រយ័ត្នថា ទឹកជន់លិចអាចនឹងកើតមានឡើង សូម្បីតែនៅតំបន់ផ្សេងក្រៅពីតំបន់ដែលរំពឹងទុកថានឹងមានការជន់លិច (តំបន់ដែលមានផាត់ពណ៌)



# ស្វែងយល់អំពីករណីគ្រោះមហន្តរាយបាក់ដី

## ប្រភេទនៃករណីគ្រោះមហន្តរាយបាក់ដី

គ្រោះមហន្តរាយបាក់ដីមាន 3 ប្រភេទ៖ ការរលំបាក់ដី ការហូរបាក់ដី និងការរអិលបាក់ដី។ ដើម្បីដោះស្រាយបញ្ហាគ្រោះមហន្តរាយបាក់ដីដែលបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរ យើងចាំបាច់ត្រូវដឹងអំពីលក្ខណៈ និងសញ្ញានៃការកើតឡើងនីមួយៗ។

### ការរលំបាក់ដី

ជាបាតុភូតមួយដែលដីត្រូវបានច្រោះដោយសារភ្លៀង ឬរញ្ជួយដី ហើយមានជម្រាលក៏រលំភ្លាមៗ។



**បាតុភូតបឋម**



ថ្មតូចៗបានធ្លាក់ពីលើជម្រាលភ្នំ (ច្រាំងថ្ម)



ទឹកផុសចេញពីជម្រាលភ្នំ (ច្រាំងថ្ម) ភ្លាមៗ ហើយទឹកផុសនោះនឹងល្អក់

### ការហូរបាក់ដី

ជាបាតុភូតមួយដែលដី និងខ្សាច់ដែលបង្កើតជាភ្នំឬទន្លេត្រូវបានរុញច្រានខ្លាំងហូរទៅជាមួយទឹកដ៏ច្រើនដែលបង្កឡើងដោយភ្លៀងធ្លាក់ខ្លាំង។ល។



**បាតុភូតបឋម**



ទឹកទន្លេល្អក់ ហើយឈើរសាត់ហូរភ្លាមៗ



ឮសំឡេងខ្យល់ភ្នំ

### ការរអិលបាក់ដី

ជាបាតុភូតមួយដែលដុំដីបង្កើតជាជម្រាល រអិលចុះជម្រាលយ៉ាងខ្លាំងដោយសារឥទ្ធិពលទឹកក្រោមដី។ល។



**បាតុភូតបឋម**



ស្នាមប្រេះលេចឡើងនៅក្នុងដី



ភ្លាមៗនោះទឹកហូរចេញដោយកន្លែងពីជម្រាលភ្នំ

## តំបន់ព្រមានគ្រោះមហន្តរាយបាក់ដី (ពិសេស)

### តំបន់ព្រមានគ្រោះមហន្តរាយបាក់ដី (ឈ្មោះទូទៅ៖ តំបន់លឿង)

ជាតំបន់ដែលកំណត់ដោយខេត្តអៃឈិ ដែលអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិត ឬរាងកាយអ្នកស្រុក។ល។ នៅពេលដែលមានគ្រោះមហន្តរាយបាក់ដីកើតឡើង។ ត្រូវបានចាត់ថ្នាក់ទៅជា «ការដួលរលំជម្រាលដ៏ចោត (ការរលំបាក់ដី)» «ការហូរបាក់ដី» និង «ការរអិលបាក់ដី»យោងទៅតាមសណ្ឋានដី។

### តំបន់ព្រមានពិសេសនៃគ្រោះមហន្តរាយបាក់ដី (ឈ្មោះទូទៅ៖ តំបន់ក្រហម)

ក្នុងចំណោមតំបន់ព្រមានអំពីករណីគ្រោះមហន្តរាយបាក់ដីនេះគឺជាតំបន់ដែលមានហានិភ័យបង្កការខូចខាតដល់អគារ និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិត ឬរាងកាយរបស់ប្រជាពលរដ្ឋ។ មានការកម្រិតទៅលើសកម្មភាពអភិវឌ្ឍន៍ដាក់លាក់ និងការដាក់កម្រិតគ្រឿងបង្គុំអគារ។

